**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៦.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង
- បានឃើញសេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

www.pheakdeylaw.com

# ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ហៅកាត់ថា **ក្រុមការងារ ខមមីត កម្ពុជា** (Cambodian COMMIT Task Force) ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **សាន្ត អរុណ** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ប្រធាន |
| ២- | ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- | លោក **គង់ នាន** | អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤- | លោកជំទាវ **សុខ ចិន្តាឡាយ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- | លោកជំទាវ **ហោ ម៉ាលីន** | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ៦- | ឯកឧត្តម **ហោ សារុន** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៧- | ឯកឧត្តម **សេង សក្ដា** | អគ្គនាយក អគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨- | ឧត្តមសេនីយ៍ទោ **ប៊ិត គឹមហុង** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- | លោកស្រី **ញឹម ទ័ាន់ចំនួតន** | អគ្គាធិការរង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- | លោកស្រី **ជា ផល្លីន** | អគ្គនាយករងវិទ្យុជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១១- | ឧត្តមសេនីយ៍ត្រី **អ៊ុច សំណាង** | នាយរងសេនាធិការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងការពារជាតិ | សមាជិក |
| ១២- | លោក **ទើង ហៀង** | ប្រធាននាយកដ្ឋានការងារកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣- | លោក **គឹម សុវណ្ណា** | អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- | លោកស្រី **ហេង ស៊ីផុន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិកអចិន្ត្រៃយ៍ |

ក្រុមការងារ ខមមីត កម្ពុជានេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី។ ក្រុមការងារ ខមមីត កម្ពុជានេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ដើម្បីដំណើរការការងារ។

www.pheakdeylaw.com

ប្រការ ២.-

ក្រុមការងារ ខមមីត កម្ពុជាមានភារកិច្ចដូចតទៅ ៖

- សហការជាមួយលេខាធិការដ្ឋាន នៃគម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពី ការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ UN Inter-Agency Project on Human Trafficking in the Greater Mekong Sub-Region (UNIAP-C) ប្រចាំកម្ពុជា ប្រចាំទីក្រុងបាងកក និងជាមួយបណ្តាដៃគូដទៃទៀតក្នុងការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស និងទេសន្តរប្រវេសន៍
- សហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ)
- រៀបចំផែនការសកម្មភាពទ្វេភាគី និងថ្នាក់មហាអនុតំបន់ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ពិសេសការជួញដូរស្ត្រី និងកុមារ ដោយប្រមូលផ្តុំនូវកិច្ចខិតខំប្រឹងប្រែងចាំបាច់នានា ដើម្បីប្រែក្លាយផែនការសកម្មភាពនេះជាការអនុវត្តជាក់ស្តែង
- ជម្រុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គឱ្យបានពេញលេញ និងមានប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់មហាអនុតំបន់ និងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និងអង្គការអន្តរជាតិក្នុងការកៀរគរជំនួយដើម្បីអនុវត្តផែនការសកម្មភាពមហាអនុតំបន់មេគង្គ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងថ្នាក់មហាអនុតំបន់មេគង្គ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស និងរាយការណ៍ជូនរាជរដ្ឋាភិបាល
- ពិនិត្យឡើងវិញនូវការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងថ្នាក់មហាអនុតំបន់មេគង្គ ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សរៀងរាល់ ៣ ឆ្នាំម្តង ហើយរាយការណ៍ជូនរាជរដ្ឋាភិបាល
- ចូលរួមក្នុងការរៀបចំផែនការសកម្មភាពជាតិ ៥ ឆ្នាំ ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

ប្រការ ៣.-

ក្រុមការងារ ខមមីត កម្ពុជា មានសិទ្ធិស្នើសុំជំនួយបច្ចេកទេស អ្នកជំនាញការអន្តរជាតិតាមការចាំបាច់ ដើម្បីជួយបណ្តុះបណ្តាល ផ្សព្វផ្សាយ និងជួយតាមដាន វាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ។

ប្រការ ៤.-

សមាជិកក្រុមការងារ ខមមីត កម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធានក្រុមការងារអាចអញ្ជើញតំណាងក្រសួងពាក់ព័ន្ធចូលរួមប្រជុំ។

www.pheakdeylaw.com

**ប្រការ ៥.-**

សេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនិងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាសមាសភាពដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com